# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ០៩ សរណន

# សារាចរណែនាំ
## ស្តីពី
## ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០

### I. បរិការណ៍នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០

*ក- ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច*

១- ការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ នេះ ស្ថិតក្នុងបរិការណ៍ដែលពិភពលោកបាន និងកំពុងជួបប្រទះវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះសេដ្ឋកិច្ចសកលលោកដែលបាន និងកំពុងធ្វើឱ្យសកម្មភាពអាជីវកម្មធ្លាក់ចុះយ៉ាងខ្លាំង និងអត្រាគ្មានការងារធ្វើកើនឡើងជាលំដាប់នៅគ្រប់ប្រទេសទាំងអស់ ហើយបាន និងកំពុងជំរុញឱ្យរដ្ឋាភិបាលនៃប្រទេសជាច្រើនប្រកាននយោបាយពង្រីកចំណាយថវិកាតាមរយៈវិធានការបង្កើនចំណាយថវិការដ្ឋជាច្រើនដើម្បីស្រោចស្រង់ស្ថានភាពដ៏លំបាកនេះ ។ នៅកម្ពុជា ដោយសារកត្តាពីខាងក្រៅ វិស័យឧស្សាហកម្ម និងសេវាកម្ម បាន និងកំពុងប្រឈមនឹងការធ្លាក់ចុះ ។ ដើម្បីកាត់បន្ថយឥទ្ធិពលអវិជ្ជមានពីខាងក្រៅនេះ ព្រមទាំងដើម្បីបង្កើនកាលានុវត្តភាព និងពង្រីកសក្តានុពលភាពនៃវិស័យទាំងពីរនេះ រាជរដ្ឋាភិបាលបានយកវិធានការតាមអភិក្រមសកម្មគ្រប់គ្រង ។ ជាក់ស្តែង សម្រាប់ការនាំចេញសំលៀកបំពាក់ ទីផ្សារអចលនទ្រព្យ សំណង់ និងទេសចរណ៍ រាជរដ្ឋាភិបាលបាន និងកំពុងបន្តជំរុញការស្វែងរកទីផ្សារ ជំរុញការវិនិយោគក្នុងស្រុក ពង្រឹងការគ្រប់គ្រងប្រព័ន្ធធនាគារ កែលម្អបរិស្ថានធុរកិច្ច កែលម្អរចនាសម្ព័ន្ធផលិតកម្ម និងកែលម្អសេវាទេសចរណ៍ ។

២- ស្ថិតក្នុងស្ថានភាពប្រកបដោយភាពមិនប្រាកដនិយមនៃសកលលោក រាជរដ្ឋាភិបាលនឹងបន្តក្តាប់ និងគ្រប់គ្រងឱ្យបាននូវសភាពការណ៍នេះ ដូចដែលរាជរដ្ឋាភិបាល ធ្លាប់បានអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងរយៈពេលតាំងពីចុងឆ្នាំ ២០០៧ រហូតមកទល់បច្ចុប្បន្ន ។ ជាពិសេស រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្ត និងបន្តដាក់ចេញនូវ គោលនយោបាយជាប្រព័ន្ធ ស៊ីសង្វាក់ និងប្រទាក់ក្រឡាគ្នា សំដៅពង្រឹងសមិទ្ធិផលជាសន្តិភាព ឯកភាពទឹកដី សន្តិសុខ បន្តធានាស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងធានានូវការពង្រឹងប្រព័ន្ធហិរញ្ញវត្ថុ ការគ្រប់គ្រងអតិផរណា ការបង្កើតឡើងនូវបរិស្ថានកាន់តែអនុគ្រោះសម្រាប់សកម្មភាពសេដ្ឋកិច្ច និងធុរៈកិច្ច ព្រមទាំងការពង្រឹង និងពង្រីកនូវប្រព័ន្ធសុវត្ថិភាពសង្គម

ជូនដល់ប្រជាពលរដ្ឋ ។ ទន្ទឹមនឹងនេះ ផ្អែកលើសមិទ្ធិផល និងបទពិសោធន៍ដែលរាជរដ្ឋាភិបាលបានកសាងក្នុងរយៈកាលជាង ៣ អាណត្តិកន្លងទៅនេះ ជាពិសេស តាមរយៈការអនុវត្តយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលពី **យុទ្ធសាស្ត្រត្រីកោណ** មក **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ១ និង ទី២** ព្រមទាំងការអនុវត្តផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលពី **ផែនការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមលើកទី ១** និង **លើកទី ២** រហូតមកដល់ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** រាជរដ្ឋាភិបាលបានបង្កើតនូវមូលដ្ឋានដ៏រឹងមាំសម្រាប់ការបន្តពង្រឹង និងជំរុញការអភិវឌ្ឍ ***ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព*** ដែលជាកត្តាគន្លឹះដ៏សំខាន់បំផុតសម្រាប់សម្រេចឱ្យបានជោគជ័យនូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ហើយសមិទ្ធិផលទាំងនេះ ពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញថា រាជរដ្ឋាភិបាលពិតជាមានគោលនយោបាយដ៏ត្រឹមត្រូវ មានការដឹកនាំដ៏ឈ្លាសវៃ និងប្រកបដោយសុឆន្ទៈមោះមុត ព្រមទាំងមានប្រព័ន្ធត្រួតពិនិត្យលទ្ធផលប្រកបដោយប្រសិទ្ធភាព ។

៣- សេដ្ឋកិច្ចកម្ពុជាកំពុងតែបន្តវិវត្តផ្លាស់ប្តូររចនាសម្ព័ន្ធ ដើម្បីឈានទៅរកដំណាក់កាលនៃការ-អភិវឌ្ឍមួយខ្ពស់ជាងមុន ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងជាលំដាប់នៃសមាមាត្រវិស័យឧស្សាហកម្ម និងសេវាកម្ម ធៀបនឹងកសិកម្ម នៅក្នុងរចនាសម្ព័ន្ធនៃផលិតផលក្នុងស្រុកសរុប (ផសស) ។ ជាក់ស្តែង ទោះជាផលិតភាពនៃវិស័យកសិកម្មបាន និងបន្តកើនឡើង តែកំណើននៃវិស័យឧស្សាហកម្ម និងសេវាកម្ម បានកើនឡើងលឿនជាងពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើឱ្យការរួមចំណែកនៃវិស័យកសិកម្មថយចុះនៅឆ្នាំ ២០០៩ មកនៅត្រឹមប្រមាណ៣៤% វិស័យឧស្សាហកម្មឡើងដល់ប្រមាណ ២១% និងវិស័យសេវាកម្មឡើងដល់៣៨% ។ ទោះជាយ៉ាងណាក៏ដោយ វិស័យកសិកម្មនៅតែជាមូលដ្ឋានសំខាន់ និងមានសក្តានុពលខ្ពស់ក្នុងការជំរុញ និងពង្រីកកំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេស នៅក្នុងបរិការណ៍ដែល វិស័យឧស្សាហកម្ម និងសេវាកម្ម បាន និងកំពុងរងឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុអន្តរជាតិ និងនៃវិបត្តិភាពសេដ្ឋកិច្ចពិភពលោក ។ ប្រការនេះ កាន់តែបញ្ជាក់ឱ្យឃើញថា ការបង្កើនទិន្នផល និងផលិតភាពកសិកម្ម ពិពិធកម្មមូលដ្ឋាននៃកំណើនវិស័យកសិកម្ម និងការជំរុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម ព្រមទាំងសហគ្រាសធុនតូច និងមធ្យម រួមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ នៅតែជាយុទ្ធសាស្ត្រដ៏សំខាន់ និងចាំបាច់ ដើម្បីបង្កើតតម្លៃបន្ថែមលើផលិតផលកសិកម្ម និងស្រូបយកពលកម្ម ដែលចេះតែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេស ពលកម្មដែលត្រូវផ្ទេរចេញពីវិស័យកសិកម្ម និងដើម្បីពង្រឹកមូលដ្ឋាន និង រក្សាចីរភាព និងសមធម៌នៃកំណើនសេដ្ឋកិច្ច ក្នុងគោលដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ស្របតាមគោលនយោបាយ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** ក៏ដូចជា **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។

៤- ឆ្នាំ ២០០៨ កន្លងទៅនេះ តាមការគណនាចុងក្រោយរបស់វិទ្យាស្ថានជាតិស្ថិតិ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានប្រមាណ ៦,៧% ទោះជាត្រូវរងនូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅតាំងពីចុងឆ្នាំ ២០០៧ រហូតមក ដូចជាកត្តាអតិផរណាខ្ពស់ ការចាប់ធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិហិរញ្ញវត្ថុអន្តរជាតិ និងវិបត្តិភាពសេដ្ឋកិច្ចពិភពលោក ដែលចាប់ផ្តើមពីសហរដ្ឋអាមេរិកក៏ដោយ ។ លទ្ធផលនេះ បានមកដោយសារវិស័យកសិកម្មបាន

កើនឡើងប្រមាណ ៥,៧% លើកំណើន ៥% នៅក្នុងឆ្នាំ ២០០៧ វិស័យឧស្សាហកម្មបានកើនឡើងប្រមាណ ៤% លើកំណើន ៨,៤% នៅក្នុងឆ្នាំ ២០០៧ (ដែលក្នុងនោះ ផលិតផលវាយនភ័ណ្ឌបានកើនឡើងត្រឹមប្រមាណ ២,២% លើកំណើន ១០% នៅក្នុងឆ្នាំ ២០០៧ ហើយផលិតផលសំណង់បានកើនឡើងត្រឹមប្រមាណ ៥,៤% លើកំណើន ៦,៧% នៅក្នុងឆ្នាំ ២០០៧) ហើយវិស័យសេវាកម្មបានកើនឡើងប្រមាណ ៩% លើកំណើន ១០% នៅក្នុងឆ្នាំ ២០០៧ (ដែលក្នុងនោះ អាជីវកម្មទេសចរណ៍ បានកើនឡើងប្រមាណ ៨,៧% លើកំណើន ៨,៩% នៅក្នុងឆ្នាំ ២០០៧) ។

៥- តាមការព្យាករណ៍ដោយមានលក្ខណៈប្រុងប្រយ័ត្ន កំណើនសេដ្ឋកិច្ចនៅឆ្នាំ ២០០៩ នេះ អាចនឹងសម្រេចបានត្រឹមប្រមាណពី ២,១% ធៀបទៅនឹងការព្យាករណ៍ ៦,៥% នៅក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។ នេះជាត្រូវទទួលឥទ្ធិពលពីខាងក្រៅ ដូចជាការធ្លាក់ចុះនៃសេដ្ឋកិច្ចអាមេរិក និងការប្រឈមនឹងការប្រកួតប្រជែងលើទីផ្សារវាយនភ័ណ្ឌពីប្រទេសវៀតណាម និងចិនក៏ដោយ ក៏កំណើននៃតម្រូវការក្នុងស្រុក និងលំហូរចូលនៃមូលធនពីក្រៅប្រទេសនឹងនៅតែបន្តកើនឡើងគ្រប់គ្រាន់ សម្រាប់រក្សាកំណើនមិនឱ្យធ្លាក់ចុះក្រោមសូន្យដែរ ។ ជាពិសេស វិស័យកសិកម្មនឹងនៅតែកើនឡើងប្រមាណ ៤,៣% វិស័យឧស្សាហកម្មនឹងធ្លាក់ចុះប្រមាណ ១% ពិសេសដោយសារការធ្លាក់ចុះនៃផលិតផលវាយនភ័ណ្ឌ និង ផលិតផលសំណង់ដែលអាចធ្លាក់ចុះប្រមាណពី ៣,៩% និង ២,៦% និងវិស័យសេវាកម្មនឹងអាចកើនឡើងប្រមាណ ៣% ។

៦- អតិផរណានៅចុងឆ្នាំ ២០០៨ បានកើនឡើងរហូតដល់ ១២,៥% (តាមឆ្នាំគោល ២០០៦) ដោយសារកត្តាឥទ្ធិពលពីខាងក្រៅនិងកត្តាកំណើនតម្រូវការក្នុងស្រុក ក៏បានរួមចំណែកក្នុងការធ្វើឱ្យថ្លៃទំនិញមួយចំនួនឡើងថ្លៃដែរ ជាពិសេស ម្ហូបអាហារ និងសំភារៈប្រើប្រាស់ ដោយសារចំណូលរបស់ប្រជាជនបានកើនឡើង និងកំណើនទេសចរណ៍ ។ តាមការព្យាករណ៍ អតិផរណាជាមធ្យមនៅក្នុងឆ្នាំ ២០០៩ នឹងធ្លាក់មកនៅត្រឹមរង្វង់ប្រមាណ ៤,៥% (តាមឆ្នាំគោល២០០៦) និងនៅឆ្នាំ ២០១០ ខាងមុខអាចនឹងស្ថិតនៅក្នុងរង្វង់ប្រមាណអត្រាមួយខ្ទង់ដដែល (៤%) ដោយសារសេដ្ឋកិច្ចពិភពលោកបានក្រឡាប់ចាក់ ១៨០ អង្សារ គឺពីអតិផរណាខ្ពស់ ថ្លៃប្រេងឥន្ធនៈខ្ពស់ និងថ្លៃស្បៀងអាហារខ្ពស់ នៅពាក់កណ្តាលឆ្នាំ ២០០៨ មករកបរិផរណា គឺការធ្លាក់ចុះនៃថ្លៃស្បៀងអាហារ និងថ្លៃប្រេងឥន្ធនៈនៅដើមឆ្នាំ ២០០៩ និងដោយសារកត្តាក្នុងស្រុកដែលរងឥទ្ធិពលពីវិបត្តិទីផ្សារហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក ដូចជាការធ្លាក់ចុះនូវចំណូលរបស់ប្រជាជន និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ ។ ប្រការនេះបាន និងកំពុងបន្តធ្វើឱ្យការវិវត្តនៃសេដ្ឋកិច្ច និងការប្រែប្រួលនៃថ្លៃវត្ថុធាតុដើមស្ថិតក្នុងភាពមិនប្រាកដប្រជា និងមានការលំបាកក្នុងការព្យាករណ៍និន្នាការ ។

## ១- __ស្ថានភាពហិរញ្ញវត្ថុសាធារណៈ និង ថវិកា__

៧- ការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពប្រុងប្រយ័ត្ន តួបផ្សំនឹងការអនុវត្តគោលនយោបាយរូបិយវត្ថុសមស្រប និង ជាពិសេស ការបន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យ៉ាងមោះមុត គ្រប់ជ្រុងជ្រោយ និងជាជំហានៗ

យ៉ាងច្បាស់លាស់ បានធ្វើឱ្យលទ្ធផលកំណើនសេដ្ឋកិច្ច លទ្ធផលវិស័យហិរញ្ញវត្ថុ និងធនាគារ ព្រមទាំងលទ្ធផលនៃការអនុវត្តថវិកាឆ្នាំ ២០០៨ សម្រេចបានយ៉ាងល្អប្រសើរគួរជាទីមោទនៈ ។ ជាក់ស្តែង កំណើនសេដ្ឋកិច្ចឆ្នាំ ២០០៨ សម្រេចបាន ៦,៧% ធៀបនឹង ៧% នៃការព្យាករណ៍សម្រាប់កសាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៨ ហើយវិស័យហិរញ្ញវត្ថុ និងធនាគារបាន និងកំពុងមានការរីកចំរើនល្អគួរឱ្យកត់សំគាល់ តាមរយៈការរីកដុះដាលនៃធនាគារពាណិជ្ជ ការកើនឡើងនៃប្រាក់បញ្ញើធនាគារ ការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធ និងសេវាធនាគារ និងការពង្រឹងការគ្រប់គ្រងធនាគារ ដែលបានផ្តល់នូវបុព្វបទជាមូលដ្ឋានចាំបាច់សម្រាប់ឈានទៅដល់ការបង្កើតមូលបត្ររដ្ឋ និងមូលបត្រឯកជន ព្រមទាំងទីផ្សារភាគហ៊ុននៅកម្ពុជា ទោះជាត្រូវរងនូវឥទ្ធិពលអវិជ្ជមានពីខាងក្រៅតាំងពីចុងឆ្នាំ ២០០៧ រហូតមក ដូចជាកត្តា អតិផរណាខ្ពស់ ការធ្លាក់ចុះនូវការនាំចេញសំលៀកបំពាក់ និងចំនួនភ្ញៀវទេសចរ ព្រមទាំងការធ្លាក់ចុះនៃ ទីផ្សារអចលនទ្រព្យ ដោយសារវិបត្តិទីផ្សារហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក ដែលបណ្តាលមកពីការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិកដូចបានពោលខាងលើក៏ដោយ ។

៨- ក្នុងការអនុវត្តថវិកាឆ្នាំ ២០០៨ កន្លងទៅនេះ ចំណូលក្នុងស្រុកសរុបសម្រេចបាន ១៣៤,៧% នៃច្បាប់ គឺមានកំណើន ៣១,៩% ធៀបនឹងឆ្នាំ ២០០៧ ហើយស្មើនឹង ១៣,៣% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធសម្រេចបាន ១៣៦,៥% នៃច្បាប់ គឺមានកំណើន ៣០,៩% ធៀបនឹងឆ្នាំ ២០០៧ ហើយស្មើនឹង ១១,២% នៃផសស និងចំណូលមិនមែនសារពើពន្ធសម្រេចបាន ១៣៣,៦% នៃច្បាប់ គឺមានកំណើន ២៧,២% ធៀបនឹងឆ្នាំ២០០៧ ហើយស្មើនឹង ១,៩% នៃផសស ។ រីឯការអនុវត្តចំណាយវិញក៏មានលក្ខណៈល្អប្រសើរផងដែរ ជាក់ស្តែង ចំណាយសរុបឆ្លងកាត់រតនាគារជាតិ អនុវត្តបានរហូតដល់ ១០៨,៩% នៃច្បាប់ គឺមានកំណើន ៣៣,៧% ធៀបនឹងឆ្នាំ ២០០៧ ហើយស្មើនឹង ១១,៥% នៃផសស ដែលក្នុងនោះ ចំណាយចរន្តអនុវត្តបាន ១១០,៥% គឺមានកំណើន ៣១,៣% ធៀបនឹងឆ្នាំ ២០០៧ ហើយស្មើនឹង ៩,៤% នៃផសស និង ចំណាយមូលធនសរុបសម្រេចបាន ៦,៣៥% នៃផសស ដែលក្នុងនោះហិរញ្ញប្បទានក្នុងប្រទេសអនុវត្តបាន ១០២,៥% ធៀបនឹងច្បាប់ គឺមានកំណើន ៤៥,៨% ធៀបនឹងឆ្នាំ ២០០៧ ស្មើនឹង ២,០៩% នៃផសស រីឯហិរញ្ញប្បទានក្រៅប្រទេសអនុវត្តបាន ១២៨,៦% ធៀបនឹងច្បាប់ គឺមានកំណើន ៧% ធៀបនឹងឆ្នាំ ២០០៧ ស្មើនឹង ៤,២៩% នៃផសស ។ លទ្ធផលនៃការអនុវត្តចំណូល និងចំណាយនេះ បានធ្វើឱ្យមានអតិរេកចរន្តស្មើនឹង ៣,៧% និងឱនភាពថវិកាសរុបស្មើនឹង ២,៤៩% នៃផសស ។ ទន្ទឹមនឹងនេះ ចំណាយតាមវិស័យដែលអនុវត្តបានគឺ វិស័យរដ្ឋបាលទូទៅសម្រេចបាន ១៦៤,៧% នៃច្បាប់ កើនឡើង ៤០,៩% ធៀបនឹងឆ្នាំ ២០០៧ ស្មើនឹង ១,៩១% នៃផសស វិស័យការពារជាតិ និងសន្តិសុខសម្រេចបាន ១៤៩,១% នៃច្បាប់ កើនឡើង ៣២,១% ធៀបនឹងឆ្នាំ ២០០៧ ស្មើនឹង ១,៩៤% នៃផសស វិស័យសេដ្ឋកិច្ចសម្រេចបាន ១៤៨,១% កើនឡើង ៦៥,១% ធៀបនឹងឆ្នាំ ២០០៧ ស្មើនឹង ១,០៥% នៃផសស និង វិស័យសង្គមកិច្ចសម្រេចបាន ១០១,៣% នៃច្បាប់ កើនឡើង ២៤,៣% ធៀបនឹងឆ្នាំ ២០០៧ ស្មើនឹង ៣,១៥% នៃផសស ។

៩- ទោះជាឆ្នាំ ២០០៩ នេះ កំណើនសេដ្ឋកិច្ចអាចនឹងសម្រេចបានត្រឹមប្រមាណ ២,១% ធៀបនឹង ៦,៥% នៃការព្យាករណ៍សម្រាប់កសាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ក៏ដោយ ក៏រាជរដ្ឋាភិបាលបាន និងកំពុងដាក់ឱ្យអនុវត្តជាបន្តបន្ទាប់នូវវិធានការមួយចំនួន ដើម្បីកាត់បន្ថយឥទ្ធិពលមកលើ

ស្ថានភាពហិរញ្ញវត្ថុសាធារណៈ ពិសេសលើការអនុវត្តថវិកា ។ ការបន្តពង្រឹងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈប្រកបដោយភាពត្រឹមត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ភ្ជាប់ជាមួយនឹងការជំរុញការកែលម្អ និងការពង្រឹងការប្រមូល និងការគ្រប់គ្រងចំណូល និងការកែលម្អ និងការពង្រឹងការអនុវត្ត និងការគ្រប់គ្រងចំណាយ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការធ្វើវិចារណកម្មចំណាយឡើងវិញសមស្រប ដើម្បីធានាឱ្យការអនុវត្តថវិកាឆ្នាំ ២០០៩ សម្រេចបានតាមគោលដៅនៃច្បាប់ហិរញ្ញវត្ថុ ។ តាមការព្យាករណ៍ចំណូលសរុបអាចនឹងសម្រេចបានលើសច្បាប់ហិរញ្ញវត្ថុប្រមាណ ៥% ដោយសារចំណូលមូលធនក្រៅប្រទេស និងចំណូលពន្ធដារ ទោះជាចំណូលក្នុងស្រុកភាគច្រើនអាចសម្រេចបានត្រឹមស្មើ នឹងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ឬ ស្មើនឹងការអនុវត្តក្នុងឆ្នាំ ២០០៨ ក៏ដោយ ។ ចំណូលក្នុងស្រុកសរុបអាចនឹងសម្រេចបានត្រឹមតែ ១២,៣២% នៃផសស ដែលក្នុងនោះ ចំណូលសារពើពន្ធនឹងសម្រេចបាន ១០,៣៩% នៃផសស (ក្នុងនោះ ចំណូលគយ និងរដ្ឋាករស្មើនឹង ៥,២៨% និងចំណូលពន្ធដារស្មើនឹង ៤,១២%) ចំណូលមិនមែនសារពើពន្ធ នឹងសម្រេចបាន ១,៤៣% នៃផសស ។ ដោយសារនយោបាយពង្រីកចំណាយសាធារណៈដើម្បីទប់ទល់នឹងវិបត្តិសេដ្ឋកិច្ច ចំណាយសរុបអាចនឹងកើនឡើងដល់ ១៨,១៧% នៃផសស គឺកើនឡើង ២៤,៤% ធៀបនឹងការអនុវត្តឆ្នាំ ២០០៨ ដែលក្នុងនោះ ចំណាយចរន្តនឹងកើនដល់ ១១,១១% នៃផសស គឺកើនឡើង ២៨,១% ធៀបនឹងឆ្នាំ ២០០៨ និង ចំណាយមូលធនសរុបអាចនឹងកើនដល់ ៧,០៦% នៃផសស គឺកើនឡើងប្រមាណ ២០% ធៀបនឹងការអនុវត្តក្នុងឆ្នាំ ២០០៨ ដែលក្នុងនោះហិរញ្ញប្បទានក្នុងប្រទេសអាចកើនដល់ ២,៨៨% នៃផសស គឺមានកំណើន ៤៩,២៤% ធៀបនឹងឆ្នាំ ២០០៨ រីឯហិរញ្ញប្បទានក្រៅប្រទេសអាចកើនដល់ ៤,១៨% នៃផសស គឺមានកំណើន ៥,៦% ធៀបនឹងឆ្នាំ ២០០៨ ។ ការអនុវត្តចំណូល និងចំណាយនេះ អាចនឹងធ្វើឱ្យមានអតិបរកចរន្តត្រឹមប្រមាណ ១,១០% នៃផសស និងឱនភាពថវិកាសរុបប្រមាណ ៥,៨៦% នៃផសស ។

## II. ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១០

### *ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច*

១០- ជារួមតាមការវាយតម្លៃ និងព្យាករណ៍របស់ប្រទេសអភិវឌ្ឍន៍មួយចំនួននៅពាក់កណ្តាលឆ្នាំ ២០០៩ នេះ សេដ្ឋកិច្ចពិភពលោកអាចនឹងចាប់ផ្តើមងើបឡើងវិញខ្លះៗ នៅក្នុងឆ្នាំ ២០១០ ខាងមុខនេះ ជាពិសេស ចំពោះបណ្តាប្រទេសនៅអាស៊ី ។ ការវាយតម្លៃ និងសេចក្តីសង្ឃឹមនេះ គឺដោយផ្អែកលើកិច្ចសហការរវាងបណ្តាប្រទេសនៅគ្រប់តំបន់ ដើម្បីជំរុញគោលនយោបាយពង្រីកចំណាយលើវិស័យសាធារណៈ ពិសេសវិស័យមានផលិតភាពខ្ពស់ និងហេដ្ឋារចនាសម្ព័ន្ធ ដែលជំរុញកំណើនសេដ្ឋកិច្ច និងចំណាយលើការការពារសុវត្ថិភាពសង្គម ព្រមទាំងការជួយស្រោចស្រង់ផលវិស័យឯកជន ។ ដោយឈរលើមូលដ្ឋានខាងលើនេះ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍សម្រាប់ការរៀបចំ សេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ក្នុងកំរិត ៣% ។ ទោះជាយ៉ាងណាក៏ដោយ ស្ថិតក្នុងបរិការណ៍ប្រកបដោយភាពមិនច្បាស់លាស់ខ្ពស់បែបនេះ រាជរដ្ឋាភិបាល នឹងបន្តពង្រឹងការតាមដាន និងគ្រប់គ្រងសភាពការណ៍

យ៉ាងម៉ត់ចត់ និងជាប្រចាំ ព្រមទាំងបន្តជំរុញការអនុវត្តប្រកបដោយភាពទន់ភ្លន់ និងបន្តដាក់ចេញនូវវិធានការថ្មីៗទៀតទៅតាមការវិវត្តនៃស្ថានភាពជាក់ស្តែង ។ ហើយទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលនៅតែប្រកាន់មហិច្ឆិតាខ្ពស់ ក្នុងការសម្រេចឱ្យបាននូវគោលដៅកំណើនសេដ្ឋកិច្ចប្រមាណ ៧% និងកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ស្របតាមគោលដៅនយោបាយនៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២** និង ការបន្តរក្សាឱ្យបាននូវស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលនៅតែជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុត ក្នុងការឈានទៅសម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ភាពសុខដុមរមនាសង្គម និងសុខុមាលភាពរបស់ប្រជាជន*** ។

១១- រាជរដ្ឋាភិបាលបានត្រៀមលក្ខណៈនឹងប្រើវិធានការគោលនយោបាយរូបិយវត្ថុ និងគោល-នយោបាយថវិកា ដើម្បីបញ្ចុះ និងគ្រប់គ្រងអត្រាអតិផរណាក្នុងកំរិតមួយសមស្រប និងដោយប្រុងប្រយ័ត្នបំផុត ដោយធានាកាត់បន្ថយក្នុងកំរិតអតិបរមានូវផលប៉ះពាល់អាក្រក់លើសេដ្ឋកិច្ចជាតិ និងលើជីវភាពរបស់ប្រជាជន ។ រីឯ អត្រាប្តូរប្រាក់ រាជរដ្ឋាភិបាល ក៏ត្រៀមនឹងប្រើវិធានការគោលនយោបាយរូបិយវត្ថុ ដើម្បីរក្សាស្ថិរភាព និងកំរិតមួយសមស្របគឺក្នុងរង្វង់ ៤១០០ រៀល ក្នុង ១ ដុល្លារអាមេរិក ក្នុងទិសដៅធានាសមត្ថភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា និងធានារក្សាតុល្យភាពរវាងផលប្រយោជន៍អ្នកមានចំណូលជាប្រាក់រៀល និងអ្នកមានចំណូលជាប្រាក់ដុល្លារអាមេរិក ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការអភិវឌ្ឍតាមវិស័យ រួមមាន ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចដែលត្រូវផ្តោតលើកសិកម្ម កសិឧស្សាហកម្ម និងការអភិវឌ្ឍជនបទ ការអភិវឌ្ឍវិស័យសង្គមកិច្ចដែលត្រូវផ្តោតលើការអប់រំ សុខាភិបាល និង ការកសាងធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលត្រូវផ្តោតលើផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ និងការអភិវឌ្ឍវិស័យឯកជន ។ លើសពីនេះ រាជរដ្ឋាភិបាល នឹងត្រូវបន្តជំរុញការអនុវត្តបណ្តាកម្មវិធីកែទម្រង់លើគ្រប់វិស័យឱ្យបានកាន់តែស៊ីជម្រៅ រួមមានការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាល សាធារណៈ និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការការកែ-ទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីសម្រេចបាននូវការគ្រប់គ្រងប្រកបដោយអភិបាលកិច្ចល្អ និងការផ្តល់សេវាសាធារណៈប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ។

## ***១- ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និង ថវិកា***

១២- ដោយផ្អែកលើមូលដ្ឋាននៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ជាពិសេស ដើម្បីបម្រើឱ្យការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គោល-នយោបាយតាមវិស័យ និងផែនការសកម្មភាពរបស់រាជរដ្ឋាភិបាល ថវិកាឆ្នាំ ២០១០ មានគោលដៅសំខាន់ៗដូចតទៅ ÷

- ធានាឱ្យបាននូវការអនុវត្តទិសដៅគោលនយោបាយ និងកម្មវិធីយុទ្ធសាស្ត្រជាអាទិភាពតាមវិស័យ នៅក្នុងក្របខ័ណ្ឌនៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ។

• ធានាការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ជាពិសេស ការអភិវឌ្ឍវិស័យអាទិភាព រួមមាន វិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការអភិវឌ្ឍវិស័យឯកជន ដើម្បីជំរុញកំណើន និង ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

• ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល ៣ ឆ្នាំ (២០១០-២០១២)

• ធានាបំរើឱ្យការបន្តសកម្មភាពកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល លើគ្រប់ផ្នែក រួមមាន កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់ច្បាប់ និងប្រព័ន្ធ តុលាការ កំណែទម្រង់វិស័យកងទ័ព និង ការអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ ដើម្បីពង្រឹង អភិបាលកិច្ចល្អ និង បង្កើនភាពស័ក្តិសិទ្ធិ និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។

• ធានាបន្តផ្តល់អាទិភាពដល់ការបង្កើន និង លើកកំពស់គុណភាពសេវាកម្មនៅក្នុងវិស័យ សង្គមកិច្ច ជាពិសេស វិស័យអប់រំ សុខាភិបាល និងការកសាងធនធានមនុស្ស ព្រមទាំង ធានាបន្តផ្តល់ អាទិភាពដល់ការបង្កើន និង លើកកំពស់សកម្មភាពដែលបំរើឱ្យវិស័យ សេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការអភិវឌ្ឍជនបទ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ។

១៣- ដើម្បីសម្រេចបានតាមគោលដៅនៃទិសដៅគោលនយោបាយខាងលើ រាជរដ្ឋាភិបាលនឹងបន្ត ជំរុញការអនុវត្តបណ្តាគោលនយោបាយ និងកម្មវិធីកែទម្រង់សំខាន់ៗ ដូចខាងក្រោមៈ

*ក.* បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ត្រឹមត្រូវ និងគោលនយោបាយហិរញ្ញវត្ថុសាធា-រណៈដ៏ប្រុងប្រយ័ត្ន គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏សមស្រប ដើម្បីធានាបន្តសម្រេចឱ្យបាននូវ កំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយចីរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាសមស្រប ។ ជាពិសេស រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្ត ព្រមទាំងបន្តត្រៀមនូវបណ្តាវិធានការគោលនយោបាយថវិកា និងរូបិយវត្ថុ សម្រាប់ទប់ទល់នឹងវិបត្តិហិរញ្ញវត្ថុ សេដ្ឋកិច្ច និងអតិផរណា ក្នុងករណីចាំបាច់ ។

*ខ.* បន្តជំរុញការអភិវឌ្ឍតាមវិស័យ ពិសេស វិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ។ ជំរុញ និងបង្កើន ការលើកស្ទួយវិស័យកសិកម្ម កសិឧស្សាហកម្ម និងជួយគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ។ បន្ត យកចិត្តទុកដាក់ខ្ពស់លើវិស័យអប់រំ សុខាភិបាល និង ការកសាងធនធានមនុស្ស ។ បន្តជំរុញការកសាង ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជាពិសេសប្រព័ន្ធស្រោចស្រព ។ បង្កបរិយាកាស និងផ្តល់ការលើកទឹកចិត្តដល់ ការអភិវឌ្ឍវិស័យឯកជន ។

*គ.* បន្តជំរុញការអនុវត្តកំណែទម្រង់ដីធ្លី និងបោសសម្អាតមីន ដោយផ្តោតសំខាន់លើការពង្រឹង ប្រព័ន្ធគ្រប់គ្រង ការបែងចែកដីធ្លីប្រកបដោយសមធម៌ ការប្រើប្រាស់ដីធ្លីប្រកបដោយប្រសិទ្ធភាព ការចុះបញ្ជី ដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការធានាសុវត្ថិភាពនៃកម្មសិទ្ធិដីធ្លី ឱ្យសមស្របតាមច្បាប់ភូមិបាល ដើម្បី ជួយគាំទ្រដល់វិស័យកសិកម្ម សំដៅលើកកម្ពស់ផលិតភាព និងពិពិធភាវូបនីយកម្មកសិកម្ម ដើម្បីឱ្យវិស័យនេះ ក្លាយទៅជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ច និងបំរើឱ្យគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ ប្រជាជន ។

*ឃ.* បន្តពង្រឹង និងពង្រីកប្រព័ន្ធធនាគារ វិស័យធានារ៉ាប់រង ទីផ្សារមូលបត្រ និងទីផ្សារភាគហ៊ុន ក្នុងក្របខ័ណ្ឌនៃការបន្តជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុទាំងមូល ដើម្បីបង្កើនការគៀរគរធនធានហិរញ្ញវត្ថុ

ប្រកបដោយប្រសិទ្ធភាព និងបង្កើនសក្តានុពលភាព និងភាពលានុវត្តភាព ដល់ការធ្វើហិរញ្ញប្បទាន និងការអភិវឌ្ឍវិស័យឯកជន ។

*ង.* បន្តអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ***ការបន្តពង្រឹងភាពជឿទុកចិត្តលើថវិកា*** នៃជំហានទី ១ តាមរយៈការបន្តជំរុញការកែលម្អនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ដើម្បីធានាឱ្យការបើកផ្តល់ថវិកាបានទាន់ពេលវេលា ។ បន្តកសាងក្របខ័ណ្ឌគោលនយោបាយចំណូលរយៈពេលមធ្យមដើម្បីរក្សាស្ថិរភាព និងនិរន្តរភាពចំណូល ពិសេសផ្តោតការយកចិត្តទុកដាក់លើការកសាង និងពង្រឹងការអនុវត្តក្របខ័ណ្ឌច្បាប់ យន្តការគ្រប់គ្រង និងប្រមូលពន្ធ និងអាករ ព្រមទាំងចំណូលមិនមែនពន្ធ រួមទាំងចំណូលពីធនធានធម្មជាតិផង ។ ទន្ទឹមនឹងនេះ ត្រូវបន្តជំរុញការអនុវត្តផែនការសកម្មភាពជំហានទី ២ គឺ ***ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ*** ព្រមទាំងបន្តជំរុញការពង្រឹង និងបង្កើនការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី ដែលជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់ ***ក្នុងការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** និង ***ការបង្កើនគណនេយ្យភាពចំពោះលទ្ធផលកម្ម*** ដែលជាគោលដៅនៃជំហានទី ៣ និងទី ៤ ។

*ច.* បន្តជំរុញការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ពិសេស ការរៀបចំរចនាសម្ព័ន្ធរដ្ឋបាល ច្បាប់ និងលិខិតគតិយុត្តិផ្សេងៗ ដើម្បីអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។ ក្នុងន័យនេះ **គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)** និង ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសហការរៀបចំកម្មវិធីសកម្មភាពឱ្យបានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ជាជំហានៗ ប្រកបដោយភាពហ្មត់ចត់ និងប្រុងប្រយ័ត្នខ្ពស់ ដើម្បីធានាការអនុវត្តប្រកបដោយភាពរលូន និង ប្រសិទ្ធភាព ។ ពិសេស ការពង្រឹងសមត្ថភាពរដ្ឋបាលបច្ចេកទេស និងហិរញ្ញវត្ថុរបស់គ្រប់ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ដើម្បីធានាការផ្ទេរអំណាច និងការទទួលខុសត្រូវពីថ្នាក់ជាតិប្រកបដោយប្រសិទ្ធភាព ។

*ឆ.* បន្តជំរុញការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អការគ្រប់គ្រងធនធានមនុស្ស ដើម្បីបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ ។ ក្នុងន័យនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលត្រូវរៀបចំគោលនយោបាយរយៈពេលមធ្យម និងវែង សម្រាប់ការកែលម្អការគ្រប់គ្រងធនធានមនុស្សប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ជាពិសេសត្រូវបង្កើតយន្តការ និងបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យក្របខ័ណ្ឌមន្ត្រីរាជការ ការពង្រឹងការផ្តល់ទិដ្ឋាការឱ្យប្រើសមន្ត្រីថ្មីបន្ថែមដោយផ្អែកលើការវិភាគលើតម្រូវការជាក់ស្តែង និងលទ្ធភាពថវិកាជាតិ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការគ្រប់គ្រងក្របខ័ណ្ឌមន្ត្រីរាជការចូលនិវត្តន៍ ។ ទន្ទឹមនឹងនេះ ត្រូវពិនិត្យពិចារណាឡើងវិញលើរាល់គោលនយោបាយ និងគោលការណ៍តម្លើង និងផ្តល់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ រួមទាំងការតម្លើងបៀវត្សបូលដ្ឋានប្រចាំខែ ការតម្លើងកាំប្រាក់ ការអនុវត្តប្រាក់បំណាច់មុខងារ ការផ្តល់ប្រាក់ឧបត្ថម្ភផ្សេងៗ ដូចជា ប្រាក់ម៉ោង ប្រាក់យាម ប្រាក់បេសកកម្ម ប្រាក់កន្សោមអាទិភាព និងប្រាក់លាភការតាមសមិទ្ធកម្ម ជាដើម ដើម្បីធានាសមធម៌ តម្លាភាព សង្គតិភាព និងប្រសិទ្ធភាព ។

៥. បន្តជំរុញការអនុវត្តកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ ពិសេស ការពង្រឹងសមត្ថភាពដឹកនាំ វិជ្ជាជីវៈជំនាញ សហប្រតិបត្តិការ និងការគ្រប់គ្រងធនធានមនុស្ស និងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ព្រមទាំងការកែសម្រួលរចនាសម្ព័ន្ធកងឯកភាពប្រយុទ្ធ និងការកាត់បន្ថយកងទ័ព ដើម្បីធានាការប្រើប្រាស់ និងគ្រប់គ្រងកងកម្លាំងប្រដាប់អាវុធប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ។

## III. ការគណនា និង ទិសដៅនៃថវិកាឆ្នាំ ២០១០

### ក- គម្រោងចំណាយថវិកា

១៤- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅទាំងអស់ខាងលើ និង ដោយផ្អែកលើ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ ២០១០ ត្រូវគ្រោង លើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម៖

- បន្តការរឹតត្បិតចំណាយចរន្ត ជាពិសេស ការបន្តលុបបំបាត់ចំណាយអត្ថិសនីទូរស័ព្ទ និងប្រេងឥន្ធនៈ ដើម្បីរក្សាចំណាយសរុបឱ្យស្ថិតនៅក្នុងកំរិត ១៨,០៧% នៃផសស គឺកើនឡើងប្រមាណ ១,៤៥% នៃផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ ដែលក្នុងនោះ ចំណាយចរន្តសរុបនឹងត្រូវបានរក្សាឱ្យនៅត្រឹមប្រមាណ ១១% នៃផសស និងចំណាយមូលធននឹងត្រូវបានរក្សានៅត្រឹមប្រមាណ ៧,០៧% នៃផសស ក្នុងទិសដៅរក្សាអតិរេកចរន្តក្នុងរង្វង់ ១,៨៩% នៃផសស និងឱនភាពថវិកាសរុបក្នុងរង្វង់ ៥,០៩% នៃផសស ។ ដោយឡែក ចំណាយមូលធនដោយហិរញ្ញប្បទានក្នុងស្រុកត្រូវកំណត់ក្នុងចំនួន ២,៦១% នៃផសស ក្នុងនោះ ចំណាយសម្រាប់រំលស់បំណុលត្រូវកំណត់ត្រឹម ០,៣១% នៃផសស ។ ហើយចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេសត្រូវកំណត់ក្នុងចំនួន ៤,១៥% នៃផសស ។
- ត្រូវវិភាជន៍ចំណាយចរន្តទៅតាមវិស័យនីមួយៗ ដូចតទៅ៖ វិស័យសង្គមកិច្ចស្មើនឹង ៣,៧០% នៃផសស មានកំណើនប្រមាណ ០,១៨% នៃផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ វិស័យសេដ្ឋកិច្ច ០,៩% នៃផសស មានកំណើនប្រមាណ ០,១១% នៃផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ វិស័យរដ្ឋបាលទូទៅ ១,៣៦% នៃផសស ប្រហាក់ប្រហែលនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ វិស័យការពារជាតិ និងសន្តិសុខ ២,៧៨% នៃផសស ថយចុះប្រមាណ ០,១% នៃផសស ធៀបនឹងការព្យាករណ៍អនុវត្តឆ្នាំ ២០០៩ ។ ថវិកាផ្ទាល់របស់រាជធានី-ខេត្ត សរុបមានប្រមាណ ០,៧៧% នៃផសស ប្រហាក់ប្រហែលនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ ។

១៥- ទន្ទឹមនឹងនេះ ថវិកាឆ្នាំ ២០១០ ត្រូវបន្តបំពេញឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ព្រមទាំងការលើកស្ទួយជីវភាពប្រជាជននៅទីជនបទ សំដៅសម្រេចឱ្យបាន នូវការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ ថវិកាឆ្នាំ ២០១០ ត្រូវផ្តល់ ការវិភាជជាក់ស្តែងទៅតាមគោលនយោបាយអាទិភាពរបស់វិស័យនីមួយៗ ដូចខាងក្រោម៖

- បន្តបង្កើនថវិកាសម្រាប់វិស័យអប់រំ និងសុខាភិបាលឱ្យស្របទៅតាមគោលដៅនៃកម្មវិធីចំណាយ រយៈពេលមធ្យមសម្រាប់វិស័យអប់រំ និង សុខាភិបាលឆ្នាំ ២០១០-២០១២ ។

- បន្តបង្កើនថវិកាសម្រាប់ការអភិវឌ្ឍប្រព័ន្ធស្រោចស្រព ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍកសិកម្ម និងការអភិវឌ្ឍជនបទ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញវិស័យសេដ្ឋកិច្ចដើម្បីកំណើន ការងារ សមធម៌ និង ការកាត់បន្ថយភាពក្រីក្រ ។
- បង្កើនមូលនិធិថវិកាឃុំ- សង្កាត់ឆ្នាំ ២០០៩ ដល់ ២,៨០% នៃចំណូលចរន្តថវិកាជាតិឆ្នាំ ២០០៩ ដែលបានអនុម័តដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ស្របតាមអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៧ ស្តីពីការផ្ទេរធនធានពីថវិកាជាតិជូនមូលនិធិឃុំ- សង្កាត់ ។
- ថវិកាខេត្ត ក្រុង ដែលរួមមានថវិកាផ្ទាល់ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិ ហើយដែលនឹងត្រូវក្លាយទៅជាថវិកា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាពេលអនាគតដ៏ខ្លីខាងមុខ នៅពេលដែលរាល់ក្របខ័ណ្ឌគតិយុត្តសម្រាប់ការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានដាក់ឱ្យអនុវត្ត ហើយរចនាសម្ព័ន្ធរដ្ឋបាល និងមុខងារត្រូវបានកំណត់ និងផ្ទេរចប់សព្វគ្រប់នោះ ត្រូវបន្តអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងរាល់នីតិវិធីដែលមានជាធរមាន ស្របតាមមាត្រា ៨៧ នៃអន្តរប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។
- បន្តផ្តល់អាទិភាពនៃការបែងចែកថវិកាដល់ថវិកាកម្មវិធី និង ផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាដែលបានបញ្ជាក់ពីទិសដៅគោលនយោបាយ គោលបំណង កម្មវិធី និង/ឬ យុទ្ធសាស្ត្រអាទិភាព ផែនការសកម្មភាព ព្រមទាំងលទ្ធផលរំពឹងទុក និង សូចនាករច្បាស់លាស់ ដើម្បីធានាការអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និង បង្កើនប្រសិទ្ធភាពថវិកា ជាពិសេស ការបន្តពង្រឹង និង ការកែលម្អការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ។

**ខ- គម្រោងចំណូលថវិកា**

១៦- ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃគំរោងចំណាយខាងលើ ត្រូវបន្តពង្រឹងការគ្រប់គ្រងចំណូល និង ជំរុញការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូល ជាពិសេស ការកសាងគោលនយោបាយចំណូល និងការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាសម្រេចឱ្យបាននូវកម្រិតចំណូលក្នុងស្រុកសរុបប្រមាណ ១៣,០២% នៃផសស គឺមានកំណើន ១% នៃផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ ដែលក្នុងនោះចំណូលសារពើពន្ធត្រូវសម្រេចឱ្យបាន ១១% នៃផសស គឺមានកំណើន ១% នៃផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ ចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន ១,៨៩% នៃផសស គឺមានកំណើន ០,០៦% នៃផសស ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០០៩ និងចំណូលមូលធនក្នុងស្រុកត្រូវសម្រេចឱ្យបាន ០,១២% នៃ ផសស ប្រហាក់ប្រហែលនឹងឆ្នាំ ២០០៩ ។

១៧- ដើម្បីសម្រេចបានតាមគោលដៅនៃការប្រមូលចំណូលសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ដែលបានកំណត់ខាងលើនេះ ត្រូវបន្តជំរុញឱ្យកាន់តែសកម្មថែមទៀតក្នុងការអនុវត្តសកម្មភាពការងារ និងបណ្តាវិធានការទាំងឡាយនៅក្នុងកម្មវិធីសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ត្រូវផ្តោតលើបណ្តាវិធានការសំខាន់ៗ មួយចំនួនដូចខាងក្រោម៖

**ទី១- ផ្នែកចំណូលពន្ធដារ:**

- បន្តពង្រឹង និងកែលម្អរដ្ឋបាលពន្ធដារ ពង្រឹងការងារសវនកម្មពន្ធ ពិនិត្យលទ្ធភាពពង្រីកមូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត ។

- បន្តពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និងប្រតិបត្តិការរបស់អគ្គនាយកដ្ឋានពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ។

- បន្តបញ្ចប់ការកសាង និងចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- បន្តពង្រឹងការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងឱ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ ។

- បន្តអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និងពង្រឹងការអនុវត្តរបបពិតនៅតាមបណ្តារាជធានី-ខេត្ត និងបន្តពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ ។

- បន្តបណ្តុះបណ្តាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលពន្ធដារឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធធំ និងមធ្យម ។

- បន្តពង្រឹងលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យប្រេង និងឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាពពីវិស័យនេះ ជាពិសេស ការបន្តពិនិត្យពិចារណាលើការធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) ដើម្បីរៀបចំបញ្ចូលពន្ធលើប្រេង និងឧស្ម័ន ។

- បន្តធ្វើការសិក្សាអំពីវិចារណកម្មបន្ត និងលទ្ធភាពវិសោធនកម្មបន្តលើច្បាប់ស្តីពីសារពើពន្ធ (ពន្ធដារ) និងបណ្តាច្បាប់ពាក់ព័ន្ធ ក្នុងគោលដៅបង្កើនចំណូលថវិកាជាតិ ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ ។

**ទី២- ផ្នែកចំណូលពន្ធគយ:**

- បន្តជំរុញការរៀបចំឱ្យបានចប់សព្វគ្រប់នូវលិខិតបទដ្ឋាននានា ដើម្បីជំរុញការអនុវត្តច្បាប់គយដែលទើបបានទទួលការអនុម័ត ។

- បន្តកែលម្អនីតិវិធីក្នុងការគ្រប់គ្រងអ្នកនាំទំនិញចេញ-ចូល ដោយតម្រូវឱ្យមានការរៀបចំជាក្រុមហ៊ុននាំចេញ-ចូល និងក្រុមហ៊ុនជើងសារច្បាស់លាស់ ដើម្បីធានានូវតម្លាភាព និងភាពងាយស្រួល ក្នុងការត្រួតពិនិត្យ និងក្នុងការយកពន្ធ និងអាករផ្សេងៗ ។

- បន្តរៀបចំកែលម្អនិងដាក់ឱ្យអនុវត្តនូវរចនាសម្ព័ន្ធចាត់តាំងថ្មីរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

- បន្តជំរុញការអនុវត្តវិធានការតឹងរឹងក្នុងការបង្កើនចំណូលពន្ធគយដូចមានៈ

*ក. បន្តពង្រឹងការអនុវត្តបណ្តាវិធានការទប់ស្កាត់ និងបង្ក្រាបអំពើគេចពន្ធ* ដោយសហការយ៉ាងជិតស្និទ្ធជាមួយនឹងកងយោធពលខេមរភូមិន្ទ កងកម្លាំងនគរបាល អង្គភាពប្រឆាំងអំពើពុករលួយ និង

អាជ្ញាធរដែនដី ។ គណៈកម្មាធិការបង្ក្រាបអំពើរត់ពន្ធ ត្រូវបន្តពង្រឹងការអនុវត្តការងាររបស់ខ្លួនឱ្យកាន់តែខ្លាំងក្លា និងប្រកបដោយប្រសិទ្ធភាពថែមទៀត ក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងការអនុវត្តភារកិច្ចនេះ ត្រូវយកចិត្តទុកដាក់ ជាពិសេស លើវិធានការកែលម្អផែនការសកម្មភាពបង្ក្រាបអំពើរត់ពន្ធដោយផ្តោតលើមុខទំនិញមួយចំនួនដែលមានវេយិទភាព ដូចជា ប្រេងឥន្ធនៈ មធ្យោបាយដឹកជញ្ជូន បរិក្ខារអេឡិចត្រូនិច និងការដាក់ចេញនូវនីតិវិធីត្រួតពិនិត្យថ្មី ។

*ខ. បន្តពង្រឹងការសហការជាមួយអគ្គនាយកដ្ឋានពន្ធដារក្នុងការចែករំលែក និងផ្លាស់ប្តូរព័ត៌មាន* រួមទាំងការប្រើប្រាស់មធ្យោបាយអេឡិចត្រូនិចស្តីពីសហគ្រាសធំៗ ដើម្បីពង្រឹងវិន័យ និងកាតព្វកិច្ចពន្ធដារ ។

*គ. បន្តរិះរក និងដាក់ឱ្យអនុវត្តនូវវិធានការច្បាស់លាស់ និងទន់ភ្លន់* លើមុខទំនិញមួយចំនួនដើម្បីរក្សាប្រភពចំណូល ។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវវិធានការពង្រឹងស្ថាប័នគយ និងរដ្ឋាករមានជាអាទិ៍ៈ បន្តការបណ្តុះ-បណ្តាល និងការបង្កើនសមត្ថភាពវិជ្ជាជីវៈ ការបំពាក់ឧបករណ៍ការងារ និងសីលធម៌របស់មន្ត្រីគយ ដើម្បីពង្រឹងសមត្ថភាពស្ថាប័ន និងរដ្ឋបាលគយ ឱ្យបានរឹងមាំ ។

- បន្តពង្រឹង និងពង្រីកការអនុវត្តស្វ័យប្រវត្តិកម្មនីតិវិធីគយ និងយន្តការគ្រប់គ្រងហានិភ័យ ដើម្បីកែលម្អប្រព័ន្ធការងារ បង្កើនប្រសិទ្ធភាពនៃកិច្ចប្រតិបត្តិការ និងលើកកំពស់គុណភាពសេវាកម្ម ជូនដល់អតិថិជន ។

- បន្តពង្រឹងយន្តការអធិការកិច្ចមុនពេលផ្ទុក ការត្រួតពិនិត្យទំនិញ ការត្រួតពិនិត្យនាវាឆ្លងកាត់ការបញ្ជូនទំនិញ ការធ្វើអធិការកិច្ចនៅនឹងកន្លែង និងការប្រមូលចំណូល ។

- បន្តពង្រឹងការងារអភិបាលកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ។

**ទី៣- ផ្នែកចំណូលមិនមែនសារពើពន្ធ:**

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ពិសេសបទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០២ បប ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការប្រមូលចំណូលមិនមែនសារពើពន្ធ ពិសេស បទបញ្ជារបស់នាយករដ្ឋមន្ត្រីលេខ ០៤ បប ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ។

- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលទាំងអស់នេះ តាមគ្រប់មុខសញ្ញាទាំងអស់ ។ ក្នុងនេះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រេសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត ។

- បន្តជំរុញដើម្បីបញ្ចប់ការងារធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋទាំងអស់ ហើយចាប់ផ្តើមធ្វើបញ្ជីសារពើភ័ណ្ឌដីរបស់រដ្ឋជាបណ្តើរៗ ដើម្បីពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការប្រមូលចំណូល។

- បន្តពង្រឹងការគ្រប់គ្រងចំណូលពីផលទុនប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈការពង្រឹងយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់បង់ចំណូលដោយត្រង់ទៅក្នុងគណនីរបស់រាជរដ្ឋាភិបាលនៅធនាគារជាតិ ហើយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការបង់ចំណូលនេះ ។

១៨- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ នេះ គឺជាឧបករណ៍ដ៏សំខាន់បំផុតសម្រាប់ឈានទៅសម្រេចឱ្យបាននូវបណ្តាគោលដៅជាអាទិភាពខាងលើ ។ នៅក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចរៀបចំឱ្យបានទាន់ពេលវេលា នូវសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។ នៅក្នុងកិច្ចដំណើរការនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាប់ផ្តើមការចរចា និងពិភាក្សារៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ជាមួយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ទាំងអស់ចាប់ពីថ្ងៃទី១៧ ខែ សីហា ឆ្នាំ ២០០៩ រហូតដល់ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ និងធ្វើកំណត់បង្ហាញនៃសេចក្តីព្រាងច្បាប់នេះ ហើយផ្ញើជូនគណៈរដ្ឋមន្ត្រីឱ្យបាននៅក្នុងសប្តាហ៍ទី ១ នៃ ខែតុលា ឆ្នាំ ២០០៩ ដើម្បីគណៈរដ្ឋមន្ត្រីពិនិត្យ និង សម្រេច ហើយផ្ញើជូនរដ្ឋសភាឱ្យបានក្នុងសប្តាហ៍ទី ១ នៃ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ដើម្បីស្ថាប័ននីតិប្បញ្ញត្តិមានពេលគ្រប់គ្រាន់ក្នុងការពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នេះឱ្យបានមុនថ្ងៃ ២៥ ខែ ធ្នូ ២០០៩ ។

**គ- បណ្តាបញ្ហាប្រឈមក្នុងការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០**

១៩- ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានធ្វើឱ្យប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំនូវការគ្រប់គ្រងចំណូល និងចំណាយ ពិសេស រាជរដ្ឋាភិបាលបានដោះស្រាយបំណុលចាស់ទាំងស្រុង និងបានបញ្ឈប់ប្រពៃណីខ្វះសាច់ប្រាក់ទូទាត់ចំណាយផងដែរ ។ ទោះជាយ៉ាងនេះក៏ដោយ យើងនៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវបន្តជំរុញ ជាពិសេស ភាពចាំបាច់ក្នុងការបង្កើនចំណូលពន្ធដារក្នុងស្រុកដើម្បីបំពេញនិន្នាការថយចុះនៃចំណូលពន្ធនាំចូល និងតម្រូវការចំណាយដែលចេះតែកើនឡើងជាលំដាប់ដែលរួមមានដូចជា÷

*ទី១-* ការបន្តជំរុញការយកចិត្តទុកដាក់លើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ឱ្យបានសមស្របដើម្បីធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល ហើយពង្រឹងការរៀបចំថវិកាឱ្យបានគ្រប់ជ្រុងជ្រោយ និងសុក្រឹត ដើម្បីកាត់បន្ថយជាអតិបរមានូវចំណាយមិនបានគ្រោងទុក និងសំដៅបំបាត់ចំណាយក្រៅគម្រោងថវិកា និងចំណាយដែលមិនចាំបាច់ ដើម្បីសម្រេចបាននូវការគ្រប់គ្រងថវិកាជាតិប្រកបដោយភាពជឿទុកចិត្តបាន គណនេយ្យភាព និងប្រសិទ្ធភាព ។

*ទី២-* ការបន្តជំរុញការរៀបចំកម្មវិធីចំណូល-ចំណាយឱ្យបានសុក្រឹត និងការអនុវត្តឱ្យបានម៉ឺងម៉ាត់ដើម្បីជាមូលដ្ឋានក្នុងការកសាងផែនការសាច់ប្រាក់ សំដៅពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ធានាបង្កើនភាពជឿទុកចិត្តបាន និងគណនេយ្យភាពលើការអនុវត្តថវិកា ។ លើសពីនេះ ការបង្កើនការគោរពយ៉ាងម៉ឺងម៉ាត់នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ពិសេសវិន័យថវិកាទាំង ១០ ។

*ទី៣-* បន្តពង្រឹងការគ្រប់គ្រងបំណុល ពិសេស ការកសាងទិន្នន័យ និងការរៀបចំកម្មវិធីសងបំណុលឱ្យបានច្បាស់លាស់ និងដោយផ្សារភ្ជាប់ទៅនឹងក្របខ័ណ្ឌនៃការរៀបចំថវិកា និងការបន្តអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការខិតខំកៀរគរជំនួយអភិវឌ្ឍន៍ ដែលមានលក្ខណៈសម្បទាន និងដែលបំរើឱ្យគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

*ទី៤-* បន្តបង្កើនចំណាយលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ជាពិសេស ចំពោះគោលនយោបាយអាទិភាព ដូចជា អប់រំ សុខាភិបាល កសិកម្ម អភិវឌ្ឍន៍ជនបទ និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធរូបវន្ត មានផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធស្រោចស្រព ដែលជាគោលបំណងនៃគោលនយោបាយ និងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ ។

*ទី៥-* ការប្រឈមនឹងស្ថានភាពវិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចពិភពលោក ដែលបាន និងកំពុងបន្តជះឥទ្ធិពលមកលើសេដ្ឋកិច្ចកម្ពុជា និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏ដូចជាការអនុវត្តថវិកាពិសេស បញ្ហាការធ្លាក់ចុះនៃតម្រូវការពិភពលោកដោយសារការបាត់បង់ការងារ ដែលបាន និងកំពុងជះឥទ្ធិពលមកលើវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ នៅកម្ពុជា ព្រមទាំងការប្រែប្រួល និងភាពមិនប្រក្រតីខ្ពស់នៃថ្លៃប្រេងឥន្ធនៈ និងម្ហូបអាហារលើទីផ្សារពិភពលោក និងបម្រែបម្រួលនៃតំលៃរូបិយប័ណ្ណអាមេរិកធៀបនឹងរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មកម្ពុជា ។

## IV- នីតិវិធី និង បច្ចេកទេសនៃការរៀបចំថវិកាឆ្នាំ ២០១០

### ក- ការគ្រោងចំណូលថវិកាឆ្នាំ ២០១០

២០- ការគ្រោងគិតចំណូលចរន្តរបស់ថវិកា អាស្រ័យលើប្រភពធនធាននៃផលិតផល ឬ ផលទុនដែលជាប្រភពចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ។ ដោយផ្អែកលើស្ថានភាពសេដ្ឋកិច្ច និងបណ្តាលក្ខខណ្ឌនៃប្រភពធនធានដូចបានលើកឡើងខាងលើ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិការបស់ខ្លួនដូចតទៅ÷

- ចំណូលសារពើពន្ធត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ÷
    - លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
    - ផលប៉ះពាល់នៃអតិផរណាមកលើមូលដ្ឋានពន្ធ
    - ការប៉ាន់ស្មានលើការអភិវឌ្ឍសេដ្ឋកិច្ចនៅពេលខាងមុខ
    - ការប្រែប្រួលដែលអាចកើតមានឡើង ព្រមទាំងការត្រួតពិនិត្យ និងពិចារណាទៅលើអត្រា និងមូលដ្ឋានប្រមូលពន្ធ
    - ចំណូលបន្ថែមដែលសង្ឃឹមថាប្រមូលបាន ដោយសារការពង្រឹង និងកែលម្អរដ្ឋបាល និងគោលនយោបាយពន្ធដារ គោលនយោបាយគយ និងរដ្ឋាករ ការធ្វើវិចារណកម្មសារពើពន្ធ និងការប្រមូលបំណុលពន្ធដែលត្រូវទារ ។

- ចំពោះចំណូលពុំមែនសារពើពន្ធ ត្រូវគិតគូរទៅតាមកិច្ចការដែលនាំឱ្យមានផលទុន ដូចជា កិច្ចសន្យាជួលសេវាកម្ម ការពង្រឹង និងកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការប្រមូលបំណុលដែលត្រូវទារជាដើម ។ល។

**ខ-ការគ្រោងចំណាយថវិកាឆ្នាំ ២០១០**

២១- ការរៀបចំគម្រោងឥណទានចំណាយថវិកា ត្រូវផ្អែកលើផែនការយុទ្ធសាស្ត្រថវិកា ដែលបានផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគណនាតម្រូវការថវិកាដោយលំអិតទៅតាមជំពូក គណនី និងអនុគណនី និងទៅតាមនាយកដ្ឋាន និងអង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត (តាមគំរូដែលភ្ជាប់មកជាមួយស្រាប់) ដោយផ្អែកលើតម្រូវការជាក់ស្តែង និងដោយផ្ទាល់ សម្រាប់បំពេញឱ្យការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ រីឯការគណនាឥណទានចំណាយ ត្រូវផ្អែកទៅលើកត្តាដែលទាក់ទងនឹងមុខសញ្ញាចំណាយ ដូចជា តារាងបុគ្គលិក បញ្ជីចុះបញ្ជីសារពើភ័ណ្ឌ និងតម្លៃសម្ភារៈនៃការផ្គត់ផ្គង់ និងត្រូវផ្អែកទៅតាមធម្មនិយាមចំណាយ ដែលបានកំណត់នៅក្នុងប្រកាស ឬ សេចក្តីណែនាំ ដូចជា ចំណាយបេសកកម្ម ចំណាយមធ្យមភាគលើគ្រែមួយរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សាសម្រាប់សិស្ស ឬ និស្សិតម្នាក់ ឬ ត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសម្រាប់ការគ្រប់គ្រងកន្លងមក ។ ជាពិសេស តម្រូវការចំណាយនីមួយៗ ត្រូវមានការវិភាគយ៉ាងល្អិតល្អន់ និងមានឯកសារគាំទ្រភ្ជាប់មកជាមួយ ដើម្បីពន្យល់ទៅតាម ជំពូក គណនី និង អនុគណនីនីមួយៗ ។

**គ- ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០១០**

២២- រាជរដ្ឋាភិបាលបានធ្វើការកំណត់នូវកញ្ចប់ថវិកា ដោយកំណត់គោលការចំណាយទៅតាមប្រភេទ និងជំពូក ដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងថវិកា សម្រាប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ធ្វើជាមូលដ្ឋានក្នុងការរៀបចំគម្រោងចំណាយលំអិតទៅតាមគណនី និងអនុគណនី និងទៅតាមនាយកដ្ឋាន និងអង្គភាព ឬ ផ្នែកនីមួយៗ ដែលចំណុះឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដើម្បីបំពេញឱ្យតម្រូវការជាក់ស្តែងក្នុងការអនុវត្តកម្មវិធីសកម្មភាពចាំបាច់ដែលត្រូវបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ។ ដូចជាឆ្នាំមុនៗដែរ ក្នុងរយៈពេលអនុវត្តថវិកានៃឆមាសទី ១ ឆ្នាំ ២០១០ នេះ នឹងមិនមានការអនុញ្ញាតឱ្យធ្វើនិយ័តភាពផ្ទៃក្នុងថវិការបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទេ ។

២៣- ក្រសួង-ស្ថាប័ននិងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវគ្រោងចំណាយទៅតាមគោលការណ៍ នៃការកំណត់កញ្ចប់ថវិកា និងបណ្តាវិធានការដូចខាងក្រោម៖

ក- ចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ត្រូវគ្រោងដោយបង្កើន ២០% លើបៀវត្សមូលដ្ឋាន ទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សថ្មីនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០០៩ ។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងដែលមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬ លាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាព ត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន ។ ប្រសិនបើមានការតម្លើងឋានៈ ឬ មានមន្ត្រីថ្មី ត្រូវគ្រោងដោយឡែក ។ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត មិនត្រូវគិតអតិផរណានៅក្នុងចំណាយបៀវត្សនេះទេ ។ ចំពោះ បុគ្គលិកអណ្តែត និងភ្នាក់ងារជាតិជាប់កិច្ចសន្យា រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈត្រូវ

ស្នើសុំការធានាចំណាយថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាមុន មុននឹងចេញលិខិតអនុញ្ញាតឱ្យក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ជ្រើសរើស និងប្រើប្រាស់ ។

**ខ**- ចំណាយសម្រាប់ការទិញ និងសេវា មួយចំនួនត្រូវគ្រោងប្រកបដោយលក្ខណៈស៊ិតស្បៀត និងសន្សំសំចៃបំផុត ពិសេសចំពោះសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ មិនត្រូវបង្កើនចំណាយលើសពីឆ្នាំកំពុងអនុវត្តទេ ។ នៅពេលអនុវត្តថវិកា ហាមដាច់ខាតមិនឱ្យមានចំណាយលើសពីឥណទានថវិកាដែលបានគ្រោងសម្រាប់មុខសញ្ញានេះ និងហាមដាច់ខាតមិន ឱ្យមានការជំពាក់បំណុលដោយទិញទំនិញ ឬសេវាមកប្រើប្រាស់នៅក្រៅបរិបថថវិកាឡើយ ។ កន្លងមកចំណាយសម្រាប់មុខសញ្ញាអគ្គិសនី ទូរស័ព្ទ ទឹក ប្រេងឥន្ធនៈ និងការទទួលភ្ញៀវ មានលក្ខណៈខ្ជះខ្ជាយ ។ ចំណាយសម្រាប់មុខសញ្ញាទាំងនេះចេះតែកើនឡើងហើយការទូទាត់មិនបានទាន់ពេលវេលាដែលនាំឱ្យមានបំណុលកកស្ទះពីមួយឆ្នាំទៅមួយឆ្នាំ ។ ដើម្បីដោះស្រាយបញ្ហានេះ ចំពោះចំណាយ អគ្គិសនី ទូរស័ព្ទ និង ទឹកត្រូវអនុវត្តនូវវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នទាំងអស់ ត្រូវសហការត្រួតពិនិត្យលើការប្រើប្រាស់បច្ចុប្បន្ន ដើម្បីរៀបចំយន្តការ និងប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និងទឹក ឱ្យបានត្រឹមត្រូវ ម៉ត់ចត់ និងប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីរកឃើញការលួចបន្តចរន្តអគ្គិសនី ទូរស័ព្ទ និងទឹកប្រើប្រាស់ផ្ទាល់ខ្លួនខុសមុខសញ្ញារបស់ក្រសួង-ស្ថាប័នណាមួយ រដ្ឋមន្ត្រីក្រសួងនោះគឺជាអ្នកទទួលខុសត្រូវចំពោះមុខនាយករដ្ឋមន្ត្រី និងចំពោះមុខរដ្ឋសភា ។ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និងក្រុមហ៊ុនទូរស័ព្ទត្រូវកាត់ផ្តាច់បណ្តាញលួចលាក់ទាំងនោះភ្លាម ហើយធ្វើរបាយការណ៍ជូនក្រសួងអាណាព្យាបាលបច្ចេកទេស និង ក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ និងចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នទាំងអស់ ត្រូវសហការគ្រោងឥណទានសម្រាប់អគ្គិសនី ទូរស័ព្ទ និងទឹក ប្រកបដោយភាពសន្សំសំចៃខ្ពស់ ដោយយកចំណាយជាក់ស្តែងពីឆ្នាំមុន ធ្វើជាពិតានហើយកាត់បន្ថយចំណាយមុខសញ្ញានេះឱ្យចុះមកនៅក្នុងកំរិតមួយសមស្រប តាមការចាំបាច់ ពិតប្រាកដរបស់ក្រសួង-ស្ថាប័ន ។

- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ អគ្គិសនីកម្ពុជា រដ្ឋាករទឹកស្វយ័ត និងក្រុមហ៊ុនផ្តល់សេវាទូរស័ព្ទ ត្រូវផ្តល់វិក្កយបត្រប្រចាំខែនីមួយៗ ឱ្យបានមុនថ្ងៃទី ១៥ នៃខែ បន្ទាប់ ។ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវធ្វើការផ្ទៀងផ្ទាត់វិក្កយបត្រ និងរៀបចំទូទាត់ឱ្យបានទៀងទាត់ និងទាន់ពេលវេលារៀងរាល់ខែ ។ ហាមដាច់ខាតមិនឱ្យមានការពន្យារការទូទាត់លើមុខសញ្ញាចំណាយនេះ ដោយយកឥណទាននេះទៅប្រើប្រាស់លើមុខសញ្ញាផ្សេង ហើយផ្ទេរបន្ទុកនេះមកលើថវិការមទេ ។

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវស្នើឡើងនូវវិធានការជាក់លាក់ ក្នុងការត្រួតពិនិត្យ និងគ្រប់គ្រងការប្រើប្រាស់អគ្គិសនី ទូរស័ព្ទ និងទឹក ដើម្បីដាក់ជូនប្រមុខនៃរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ហើយដាក់ឱ្យគ្រប់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលអនុវត្តឱ្យបានខ្ជាប់ខ្ជួន និងម៉ឺងម៉ាត់បំផុត ។

**គ**- ចំពោះចំណាយសម្រាប់ជំពូក គណនី និង អនុគណនីផ្សេងៗទៀត ត្រូវគ្រោងទៅតាមតម្រូវការចាំបាច់ដោយផ្អែកលើមូលដ្ឋានផែនការសកម្មភាពដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ក្នុងករណី

តម្រូវឱ្យមានកំណើន ដោយមានការវិភាគ និងពន្យល់ច្បាស់លាស់ ក៏កំណើននោះមិនត្រូវឱ្យលើសពី ៣% នៃកញ្ចប់ថវិកាដែលបានអនុម័តឆ្នាំ ២០០៩ ដែរ ។ ចំពោះក្រសួងដែលត្រូវបន្ត ឬ ចាប់ផ្តើមអនុវត្តសាកល្បងថវិកាកម្មវិធី ត្រូវញែកគម្រោងចំណាយជាពីរផ្នែកសម្រាប់ថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី ទៅតាមគ្រប់ជំពូក គណនី និងអនុគណនីនីមួយៗ ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវអញ្ជើញក្រសួងទាំងនេះ មកការពារគម្រោងថវិកាកម្មវិធីដោយឡែក ។

ឃ- ឯកសារផែនការយុទ្ធសាស្ត្រថវិកា គម្រោងចំណូល និងគម្រោងចំណាយថវិកា ដែលក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាមូលដ្ឋានសម្រាប់ការពិភាក្សានៅក្នុងកិច្ចប្រជុំការពារថវិកា ដើម្បីការពារកញ្ចប់ថវិការបស់ខ្លួន ។ ដូច្នេះ ក្នុងករណីដែលក្រសួង-ស្ថាប័ន ឬមន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនបានបំពេញ និងផ្តល់ព័ត៌មានគ្រប់គ្រាន់សម្រាប់ការប្រជុំការពារថវិកាទេ នោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជូនព័ត៌មានទៅអង្គភាពឱ្យបានទាន់ពេលវេលា ដើម្បីបំពេញបន្ថែម ហើយប្រសិនបើនៅតែមិនអាចបំពេញបានទេនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិគ្រប់គ្រាន់ក្នុងការយកមូលដ្ឋាននៃថវិកាឆ្នាំ ២០០៩ ហើយប្រើគោលការណ៍កំណត់កញ្ចប់តាមជំពូក គណនី និងអនុគណនីខាងលើ សម្រាប់កំណត់គម្រោងថវិការបស់អង្គភាពនោះ ដើម្បីជាមូលដ្ឋានសម្រាប់ការប្រជុំការពារថវិកា និងរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុឱ្យបានទាន់ពេលវេលា ។

**ឃ- ការរៀបចំ និង ការវិភាគសំណើនានា**

២៤- ថវិកាកំពុងប្រព្រឹត្តទៅឆ្នាំ (n-1) ឆ្នាំ ២០០៩ តាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/១២០៨/០២០ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ត្រូវធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០១០ ឆ្នាំ (n) ដើម្បីធានាឱ្យសេវាសាធារណៈនានាអាចដំណើរការទៅបាន ។ ក្រសួង-ស្ថាប័ន ត្រូវតែផ្អែកលើថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ និងការណែនាំទាំងឡាយខាងលើនេះ សម្រាប់ធ្វើជាមូលដ្ឋាន ដោយគ្រាន់តែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងបណ្តាមូលហេតុដូចខាងក្រោម ÷

- ចលនាឥណទានដែលបានធ្វើឡើងក្នុងឆ្នាំកំពុងប្រព្រឹត្តដូចជា÷
  - ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬ ពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើឱ្យការបែងចែកឥណទានដើមនៃក្រសួង-ស្ថាប័ន ព្រមទាំងមន្ទីរជំនាញរាជធានី-ខេត្តមានការប្រែប្រួល ។
  - ការផ្ទេរឥណទានថវិកាបន្ថែមសម្រាប់ផលប្រយោជន៍របស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ។
- ផលប៉ះពាល់ជាយថាហេតុនៃអតិផរណានៅក្នុងឆ្នាំទៅលើថ្លៃនៃផលិតផលចាំបាច់ ដូចជា អគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន និងចំណាយរដ្ឋបាល ។ ល ។

២៥- គម្រោងថវិការបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចមានចែងខាងលើនេះ ហើយរាល់សំណើបន្ថែមត្រូវតែមានការពន្យល់បញ្ជាក់ភ្ជាប់មកជាមួយ នូវរាល់កង្វះខាតឥណទានថវិកានៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ ដែលអាចយកមកពិភាក្សាបានលុះត្រាតែមាននៅ ក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

២៦- ឥណទានថវិកាដែលបានគិតគូរដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួល អាស្រ័យដោយមានការពង្រីកសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬ មានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្តើម អនុវត្តនៅក្នុងឆ្នាំនៃផែនការ ។

២៧- បច្ចេកទេសវិភាគដ៏ទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជា ចំណាយដំណើរការរដ្ឋបាល សម្រាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃចំណាយ និងអត្ថប្រយោជន៍នៃចំណាយចាំបាច់ មួយចំនួន សម្រាប់ធ្វើជាមូលដ្ឋានគ្រោងគិតសម្រាប់ឆ្នាំផែនការ ។ ជាពិសេស ឥណទានថវិកាចាំបាច់របស់ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ត្រូវតែបំពេញទៅលើ÷

- ទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកា
- កម្មវិធី និងយុទ្ធសាស្ត្រអាទិភាពដែលបានកំណត់ច្បាស់លាស់ ដើម្បីសម្រេចបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន
- ផែនការសកម្មភាព និងពេលវេលាចាយដំណើរការ ដើម្បីអនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព
- ការគ្រប់គ្រង ការតាមដាន ការវាយតម្លៃ និងការធ្វើរបាយការណ៍ដើម្បីបង្ហាញពីលទ្ធផលនៃការ អនុវត្តកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ដែលជាមូលដ្ឋានសម្រាប់សម្រេចបានគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។

## V- សេចក្តីសន្និដ្ឋាន

២៨- ខ្លឹមសារនៃសារាចរណែនាំនេះ បានផ្តល់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ ព្រមទាំងគោលការណ៍ និងនីតិវិធីក្នុងការគ្រោងចំណូល និងចំណាយចាំបាច់សម្រាប់ជា មូលដ្ឋាន ដល់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដើម្បីរៀបចំផែនការសកម្មភាពការងារប្រចាំឆ្នាំ របស់ខ្លួនឱ្យឆ្លើយតបទៅនឹងកម្មវិធីយុទ្ធសាស្ត្រអាទិភាព ព្រមទាំងទិសដៅ និងគោលបំណងនៃគោល-នយោបាយតាមវិស័យ និងតាមផ្នែករៀងៗខ្លួន សំដៅបំពេញឱ្យបានសម្រេចនូវគោលដៅ **ផែនការយុទ្ធសាស្ត្រ អភិវឌ្ឍន៍ជាតិ** ក៏ដូចជាគោលដៅនៃ **យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព** របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យគឺ ការរក្សាកំណើនប្រកបដោយចីរភាព ក្នុងរង្វង់ប្រមាណ ៧% និងការកាត់បន្ថយភាពក្រីក្រឱ្យបានជាង ១% ក្នុងមួយឆ្នាំៗ ព្រមទាំងការបន្តរក្សា ឱ្យបាននូវស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ដែលជាមូលដ្ឋានគន្លឹះ និងចាំបាច់បំផុត ក្នុងការឈានទៅ សម្រេចបាននូវគោលដៅចុងក្រោយរបស់រាជរដ្ឋាភិបាលគឺ ***ភាពសុខដុមរមនាសង្គម និង សុខុមាលភាពរបស់ ប្រជាជន*** ។ ដូច្នេះ ដើម្បីឱ្យធនធាននេះអាចប្រើប្រាស់ប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់នោះ ទាមទារឱ្យគ្រប់ក្រសួង-ស្ថាប័នទាំងអស់មានទិសដៅ និងគោលបំណងនៃគោលនយោបាយរបស់ខ្លួនយ៉ាង ច្បាស់លាស់ដែលផ្សារភ្ជាប់ទៅនឹង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** មានកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព ជាក់លាក់ ព្រមទាំងផែនការសកម្មភាពត្រឹមត្រូវ ក្នុងការអនុវត្តឆ្ពោះទៅសម្រេចឱ្យបាននូវគោលបំណង និង ទិសដៅនៃគោលនយោបាយរបស់ខ្លួន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តជំរុញការលើកកម្ពស់អភិបាលកិច្ច

ល្អ តាមរយៈកម្មវិធីកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ជាពិសេស ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីបង្កើនភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ជូនប្រជាពលរដ្ឋ ។

២៩- ពេលទទួលសារាចរណែនាំនេះ ***គ្រប់ក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត ត្រូវរៀបចំជាបន្ទាន់នូវគម្រោងចំណូល- ចំណាយថវិការបស់ខ្លួន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ទៅតាមតារាងគំរូដែលភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ជូនពីរច្បាប់យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩*** ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សាកម្រិតជំនាញ និងបូកសរុបសម្រាប់ការចរចាចាប់ពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៩ រហូតដល់ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ ។ តួលេខគំរោង ចំណូល- ចំណាយថវិកាត្រូវសរសេរជាលេខអន្តរជាតិ (1, 2, 3...) ហើយឯកតាទាបបំផុតគិតត្រឹម 0,1 លាន រៀល ។ ក្នុងការអនុវត្តសារាចរណែនាំនេះ ប្រសិនបើក្រសួង- ស្ថាប័ន និងមន្ទីរជំនាញរាជធានី- ខេត្ត មានចំណុច ណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា ) ។

*ធ្វើនៅភ្នំពេញ, ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០០៩*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា

"*ដើម្បីជូនជ្រាប*"

- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់អភិបាលរាជធានី-ខេត្ត
- គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

"*ដើម្បីអនុវត្ត*"

- ឯកសារ-កាលប្បវត្តិ